# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ដោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ឃុនពិពទ្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ លោកអាចារ្យ កៅ-ស៊ឹម អ្នកត្រួតត្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — *ទំព័រ*

| | | |
|---|---|---|
| ឃុនពិពទ្ធមន្ត្រី ញ៉ុក-ថែម . . . | ប្រជុំសុភាសិតខ្មែរ, តាមលំដាប់អក្សរ . . . | ៦៦៦ |
| . . . . . . . . . . . . . . . | និទានរឿងព្រេងខ្មែរ : | |
| | រឿងខេបោរស៊ីផងញា . . . . . . . . . . . | ៦៧៣ |
| | រឿងឆ្មាំងវែងអន្ទង់វែង : . . . . . . . . . . | — |
| អ្នកអាចារ្យ ឌឹម-អាន . . . . . | រឿងព្រះបាទអសោកមហារាជ (តមកនឹងចប់) | ៦៧៩ |

*ផ្នែកសាសនា*

| | | |
|---|---|---|
| ព្រះអាចារ្យ ម៉ុញ-ណាគ្រី. . . . . | សុជាតាជាតក (តមកនឹងចប់) . . . . . . . | ៧០៩ |
| ព្រះគ្រូញាណសំវរៈ ញាណ-ឈឹន | លោកធម្មសូត្រ (តមក) . . . . . . . | ៧១១ |
| ដំណឹងពីក្រសួងធម្មការ. . . . . | អំពីរបៀបតាំងហៅអធិការនិងមន្ត្រីសង្ឃ . . . | ៧១៨ |
| . . . . . . . . . . . . . . . | ដំណឹងផ្សេង ៗ . . . . . . . . . . . . . . . | ៧២០ |

ឆ្នាំគំរប់ទី ១៨ — លេខ ១២ ខែដិសេមប្រ៍ ១៩៤៣ — ដំឡៃជាវៈ ១ ឆ្នាំ ១០ រៀល ។

# លោកធម្មសូត្រ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការថ្វាយបង្គំ ចំពោះព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

មុននឹងពណ៌នាសេចក្ដីក្នុងលោកធម្មសូត្រនេះ, ខ្ញុំសូមដំកល់សេចក្ដីជាបុព្វយោគទេសនា, ឲ្យមានចំនងស្រួលបន្តិចទុកជាខាងដើមសិន សន្សឹមរៀបរៀងសូត្រនេះតាមលំដាប់តទៅ ។

សេចក្ដីថាៈ ចំណោមមនុស្សយើងក្នុងលោកសន្និវាសទាំងមូល រមែងមានសន្តានចិត្តកើតកើន, ឡើង ៗ ចុះ ៗ ញ៉ង ៗ ផត ៗ ដោរ ៗ ខាប ៗ តាមចំនងដែលបានជួបប្រទះនឹងលោកធម៌នោះៗមកប៉ះពាល់ ម្ល៉ោះហើយ សន្តានចិត្តរបស់យើងមិនងាយនឹងទប់នៅនឹងបានឡើយ, គួរនាដូចរូបខ្វង, តែងតែទន់ងាករេតាមចំនងខ្យល់បក់មកត្រង់ដូច្នោះដែរ ។

មួយទៀត, មនុស្សយើងបើនឹងចែកចេញជាជាន់ ជាថ្នាក់ៗ ទៅបាន ៣ ថ្នាក់ គឺថ្នាក់ជាន់ទាប, ជាន់មធ្យម, ជាន់ខ្ពស់ ។

ថ្នាក់ជាន់ទាប, បានដល់ពួកមនុស្សដែលមានចិត្តស្រាល មិនធ្ងន់ធ្ងរ មានសន្តានកក់មិនជ្រៅ ទាំងត្រចៀកក៏ស្រាល ក្រោធខឹងក៏ងាយ ជឿក៏ងាយ, ជាក៏ងាយ អរក៏ងាយ ភ័យក៏ងាយ; មនុស្សក្រុមនេះ គួរនាដូចជាតិឈើស្រាយសុទ្ធមានដើមតរ, រកាជាដើម មានឫសកក់,

ឈើទាំងនេះមិនមូនទាំសោះ ទន្ទឹងតែត្រូវរលំទឹងអាសរលើងលំមួយរំពេចមិនយឺតយូរឡើយ, ទាំងសាច់ឈើក៏ប្រើការមិនជាប់ស្ថិតស្ថេរដែរ ។

ថ្នាក់ជាន់មធ្យម, បានដល់ពួកមនុស្សដែលមានចិត្តមិនស្រាល-មិនធ្ងន់ពេក មានសន្ដានមិនកក់មិនក្ដៅពេក ទាំងត្រចៀកក៏មិនស្រាលពេក កណ្ដាលៗ មានការពឹងពែងធ្លាយគ្រាន់បើ មិនរឹង, មិនជា, មិនជៀ, មិនអា, មិនកំសាយៗ មនុស្សក្រុមនេះ គួរនាដូចជាតិឈើមានខ្លឹមខាងក្រៅ គឺដើមឫស្សីដើមស្លាដូងត្នោតជាដើម, ឈើទាំងនោះមានឫសមិនក្រៀមមិនកក់ គ្រាន់តែសាញប្រផាញតាក់ស្រែះនៅលើគ្នាប៉ុណ្ណោះ ធន់ទ្រាំនឹងរលំព្យុះបានខ្លះ មិនងាយនឹងរលើងរលំទៅភ្លាមៗឡើយ, ទាំងសាច់ឈើក៏ប្រើការបានសម្រេចប្រយោជន៍ ប្រហែលឈើស្រាយសុទ្ធក៏មាន ជាប់ជាងក៏មាន ។

ថ្នាក់ជាន់ខ្ពស់, បានដល់ពួកមនុស្សដែលមានសន្ដានធ្ងន់ធ្ង ទឹងនួន មិនរើតរើងឡើងៗ ចុះៗ ព្រើងៗ ផតៗ ដោរៗ នាបៗ ដោយងាយឡើយ ស្មឹងមានគំនិតថ្លឹងថ្លែងមើលរកហេតុផលគួរមិនគួរ ទឹងសេចក្ដីចំរើន វិនាស, លុះយល់ច្បាស់លាស់ពិតៗហើយ ទើបអនុវត្តទៅតាមទំនងនោះៗ; មនុស្សក្រុមនេះ គួរនាដូចជាតិឈើមានខ្លឹមខាងក្នុង គឺៈ គគីរ ធ្នង់, កំពីងខ្លាជាដើម មានឫសក្រៅ មានសាច់ជាប់ ឈើទាំងនេះ

ប្រការបានច្រើនយ៉ាង អ្នកប្រទេសតែងកំពាន តែងប្រាថ្នាគ្រប់ៗគ្នា ហើយមិនងាយនឹងរលើងរលំដោយខ្យល់ព្យុះឡើយ ៖ មនុស្សយើងក្នុងលោកសន្និវាសតាំងមូលនេះ ប្រៀបដូចជាដើមឈើទាំង ៣ ពួក, លោកធម៌ប្រៀបដូចខ្យល់ព្យុះបក់មកប៉ះពាល់ដូច្នោះឯង ។ ពុំនោះសោតលោក-ធម៌គួរនាដូចជាថ្នាំពុល តែងធ្វើមនុស្សឲ្យពុលគ្រប់ជាន់គ្រប់ថ្នាក់មិនថាថ្នាក់ណាឡើយ ។

ទើបព្រះសុគតជាម្ចាស់ ទ្រង់ត្រាស់សំដែងលោកធម្មសូត្រនេះ ដោយមានពុទ្ធអធ្យាស្រ័យ ដើម្បីនឹងធ្វើសត្តនិករដែលទៅក្នុងពុទ្ធសាសនា-ខេត្តរបស់ព្រះអង្គឲ្យចេះកល់-ថ្លឹង-រស់ ស្ទង់ទៅតាមគួរនឹងទម្ងន់ដ៏ពៅនៃលោកធម៌, នៅវេលាដែលបានជួបប្រទះហើយនោះៗ ដូចនឹងរៀបរៀងតទៅនេះ ។

លោកធម្មសូត្រ. អ. អដ្ឋកនិបាត.

អដ្ឋិមេ ភិក្ខវេ លោកធម្មា លោកំ អនុបរិវត្តន្តិ លោកោ ច អដ្ឋលោកធម្មេ អនុបរិវត្តតិ ។ល។

សេចក្តីថា: "ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំងឡាយ៨ប្រការនេះ រមែងជាប់ជិតដោយតាមសត្វលោក ឯសត្វលោកក៏រមែងជាប់ជិតដោយតាមលោកធម៌ទាំង៨ប្រការ (នេះ) នឹងគេចវេះមិនផុតតែមិនរួចឡើយ"។

ប្រាំបីប្រការតើអ្វីខ្លះ? គឺមានលាភ ១ ឥតលាភ ១ មានយស ១ ឥតយស ១ គេនិន្ទា ១ គេសរសើរ ១ សេចក្ដីសុខ ១ សេចក្ដីទុក្ខ ១ រួមត្រូវជា ៨ ប្រការដូច្នេះ ។ លុះទ្រង់សំដែងជាកថេតុកាម្យតាបុច្ឆា (១) ដណ្ដឹងសួរព្រះអង្គឯង ដោះសារចំពោះព្រះអង្គឯងរួចហើយ ទើបទ្រង់និពន្ធគាថាដូច្នេះថា:

លាភោ អលាភោ ច យសាយសោ ច
និន្ទា បសំសា ច សុខំ ទុក្ខញ្ច
ឯតេ អនិច្ចា មនុជេសុ ធម្មា
អសស្សតា វិបរិណាមធម្មា
ឯតេ ច ញត្វា សតិមា សុមេធោ
អវេក្ខតិ វិបរិណាមធម្មេ

---

១— បុច្ឆាមាន ៣ គឺអទិដ្ឋជោតនាបុច្ឆា ១ ទិដ្ឋសំសន្ទនាបុច្ឆា ១ វិមតិច្ឆេទនាបុច្ឆា ១ ។ ៣ ពីរទៀតគឺមនុស្សបុច្ឆា ១ អមនុស្សបុច្ឆា ១ និម្មិតបុច្ឆា ១ ។ ៥ យ៉ាងទៀតគឺ អទិដ្ឋជោតនាបុច្ឆា សួរដើម្បីបំភ្លឺសេចក្ដីដែលខ្លួនមិនទាន់ដឹងមិនទាន់ឃើញ ឲ្យច្បាស់លាស់ឡើង ១, ទិដ្ឋសំសន្ទនាបុច្ឆា សួរតាមដែលបានដឹងបានឃើញ ដើម្បីនឹងប្រៀបផ្ទឹមដោយអ្នកប្រាជ្ញដទៃ ១, វិមតិច្ឆេទនាបុច្ឆា សួរដើម្បីនឹងវិច្ឆេទ័យនូវសេចក្ដីសង្ស័យ ១, អនុមតិបុច្ឆា សួរប្រែបណ្ដោយតាមឆ្លើយទ្រស្រុបបណ្ដោយតាមសួរ, ដូចសួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់ថារូបទៀងឬមិនទៀងរ?", ឆ្លើយថា "មិនទៀងទេព្រះអង្គដ៏ចំរើន ជាដើម ១, កថេតុកម្យតាបុច្ឆា សួរដើម្បីសំដែងចំពោះព្រះអង្គឯង, ដូចពាក្យថា "ម្នាលភិក្ខុទាំងឡាយសតិបដ្ឋានមាន ៤ យ៉ាង ។ នោះតើដូចម្ដេច? ជាដើម ១ ។

ឥដ្ឋស្ស ធម្មា ន មថេន្តិ ចិត្តំ
អនិដ្ឋតោ នោ បដិឃាតមេតិ
តស្សានុរោធា អថវា វិរោធា
វិធូបិតា អត្ថគតា ន សន្តិ
បទញ្ច ញត្វា វិរជំ អសោកំ
សម្មប្បជានាតិ ភវស្ស បារគូតិ ៕

សេចក្តីថា: លោកធម៌ទាំងឡាយនេះគឺ មានលាភ ១ ឥតលាភ ១ មានយស ១ ឥតយស ១ គេនិន្ទា ១ គេសរសើរ ១ សេចក្តីសុខ ១ សេចក្តីទុក្ខ ១ ជាធម៌មិនទៀងទាត់ មិនស្ថិតស្ថេរ តែងតែប្រែប្រួលជាធម្មតា (ធ្លាក់សង្កត់) លើពួកមនុស្សពាលឥតស្មារតី. អ្នកប្រាជ្ញមានស្មារតី ក្រាក់ខ្លួន (លោក) ស្គាល់នូវលោកធម៌ទាំងនេះផង, ពិចារណាសភាពប្រែប្រួលនៃលោកធម៌ទាំងនេះផង; (ទើប) ធម៌ជាទីប្រាថ្នា ញាំញីចិត្ត (របស់លោក) មិនបាន, លោកមិនបានដល់នូវសេចក្តីបង្អៀតបង្អល់ចិត្ត ព្រោះធម៌មិនជាទីប្រាថ្នាឡើយ, លោកបន្សាត់បោលសេចក្តីត្រេកអរ ទាំងបន្សាត់បោលសេចក្តីថាំងថ្នាក់ក្នុងចិត្ត ទាំងធ្វើឲ្យអស់ទៅមិនឲ្យមានតទៅទៀតឡើយ, លោកជ្រាបច្បាស់នូវបទគឺព្រះនិព្វានដែលប្រាសចាកធូលីគឺកិលេស, មិនមានសេចក្តីសោក ជាអ្នកឆ្លងដល់ត្រើយនៃភព, តែងជ្រាបច្បាស់ដោយប្រពៃ ៕

កាលដែលទ្រង់សំដែងនិព្វានគាថានេះចប់ស្រេចហើយ ទើបទ្រង់ប្រោសនិគមវចនៈ សំដែងជូនថែមទៀត សេចក្តីដែលខ្វះ មានពិស្តារជាងសូត្រមុនខ្វះ ។

ឯសេចក្តីពិស្តារថា៖ ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ ប្រការ គឺ មានលាភ ឥតលាភជាដើម តែងកើតឡើងដល់បុគ្គលជាបុថុជ្ជនអ្នកមិនចេះ-ដឹងផង, តែងកើតឡើងដល់អរិយសាវកអ្នកចេះ-ដឹងផង មិនវៀរលែងនបំពួកណាមួយឡើយ, ហើយទ្រង់ចោទវណ្ណីដំណោះភិក្ខុ-សង្ឃ ដើម្បីបំភ្លឺសេចក្តីតទៅទៀតថា ម្នាលភិក្ខុទាំងឡាយចុះត្រង់អរិយ-សាវកអ្នកចេះ-ដឹង និងបុថុជ្ជនអ្នកមិនចេះ-ដឹងមានសេចក្តីផ្សេងគ្នា, លើសខុសគ្នា, ខុសពីគ្នាដូចម្តេចទៅ? ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះលោកនាថជាម្ចាស់ដ៏ចំរើន ខ្ញុំព្រះអង្គទាំងអម្បាលនេះ បានព្រះអង្គជាប្រធាន បានព្រះអង្គជាអ្នកដឹកនាំ បានព្រះអង្គជាទីពឹងផ្អែក, គឺបើលោះនេះ សូមមានតែព្រះអង្គទ្រង់បំភ្លឺសេចក្តីនៃភាសិត (នេះ) ឲ្យបានភ្លឺក្នុងព្រះអង្គជាភិក្ខុទាំងអស់គ្នា លុះបានស្តាប់ភាសិតរបស់ព្រះអង្គហើយនឹងបានចាំទុកតទៅ" ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បើដូច្នោះអ្នកទាំង-ឡាយចូរប្រុងស្តាប់, ចូរធ្វើទុកក្នុងចិត្តឲ្យស្រួលបួលចុះ តថាគតនឹងសំដែងឲ្យស្តាប់" ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាថា "ព្រះករុណាព្រះអង្គ" ។

ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ លាភរមែងកើតឡើងដល់បុថុជ្ជនអ្នកមិនចេះដឹង, បុថុជ្ជននោះមិនចេះពិចារណា មិនដឹងច្បាស់តាមពិតថា លាភនេះកើតឡើងដល់អាត្មាអញពិតហើយ តែលាភនោះជារបស់មិនទៀងជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា, អលាភ, មានយស, អយស, គេនិន្ទា គេសរសើរ, សេចក្ដីសុខ, សេចក្ដីទុក្ខ រមែងកើតឡើងដល់បុថុជ្ជនអ្នកមិនចេះដឹង, បុថុជ្ជននោះមិនចេះពិចារណា មិនដឹងច្បាស់តាមពិតថា សេចក្ដីទុក្ខនេះកើតឡើងដល់អាត្មាអញពិតហើយ តែសេចក្ដីទុក្ខនេះជារបស់មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា; ទើបលាភក្ដី អលាភក្ដី មានយសក្ដី អយសក្ដី គេនិន្ទាក្ដី គេសរសើរក្ដី សេចក្ដីសុខក្ដី សេចក្ដីទុក្ខក្ដី រមែងគ្របសង្កត់ចិត្តរបស់បុថុជ្ជននោះៗ តែងត្រេកអរនឹងលាភដែលកើតឡើង តែងថ្នាំងថ្នាក់តូចចិត្តក្នុងអលាភ, តែងត្រេកអរនឹងយសដែលកើតឡើង តែងថ្នាំងថ្នាក់តូចចិត្តក្នុងអយស, តែងត្រេកអរនឹងពាក្យសរសើរដែលកើតឡើង តែងថ្នាំងថ្នាក់តូចចិត្តក្នុងពាក្យនិន្ទា, តែងត្រេកអរនឹងសេចក្ដីសុខដែលកើតឡើង តែងថ្នាំងថ្នាក់តូចចិត្តក្នុងសេចក្ដីទុក្ខ; បុថុជ្ជននោះទទួលត្រឹមតែយកសេចក្ដីត្រេកអរ នឹងសេចក្ដីថ្នាំងថ្នាក់តូចចិត្ត ដូចពណ៌នាមកហើយយ៉ាងនេះ មិនរួចផុតចាកជាតិជរាមរណៈ សេចក្ដីសោក

ខ្សឹកខ្សួល ទុក្ខទោមនស្ស សេចក្ដីចង្អៀតចង្អល់ទាំងឡាយឡើយ, តថាគតហៅថា បុគ្គលនោះមិនរួចចាកទុក្ខទេ» ។

ម្នាលភិក្ខុទាំងឡាយ ក៏ឯលោកធម៌ទាំង ៨ ប្រការគឺ មានលាភជាដើម រមែងកើតឡើងដល់អរិយសាវកអ្នកចេះ-ដឹង (ដូច្នោះដែរ), គឺអរិយសាវកនោះ (លោក) ចេះពិចារណា (លោក) ដឹងតាមពិតថា លាភនេះកើតឡើងដល់អាត្មាអញពិតមែនហើយ តែលាភនោះ ជារបស់មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា ៖ ឥតលាភ មានយស ឥតយស ពាក្យសរសើរ ពាក្យនិន្ទា សេចក្ដីសុខ សេចក្ដីទុក្ខ រមែងកើតឡើងដល់អរិយសាវកនោះៗ លោកចេះពិចារណា លោកដឹងច្បាស់តាមពិតថា សេចក្ដីទុក្ខនេះ កើតឡើងដល់អាត្មាអញពិតមែនហើយ តែសេចក្ដីទុក្ខនោះជារបស់មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា, ទើបមានលាភជាដើមក្ដី រមែងមិនគ្របសង្កត់ចិត្តរបស់អរិយសាវកនោះបានឡើយ ៖ ទាំងអរិយសាវកនោះសោតទៀត លោកក៏មិនត្រេកអរនឹងលាភដែលកើតឡើង មិនថ្នាំងថ្នាក់ក្នុងចិត្តនឹងឥតលាភ, មិនត្រេកអរនឹងយសដែលកើតឡើង មិនថ្នាំងថ្នាក់ក្នុងចិត្តនឹងឥតយស, មិនត្រេកអរនឹងពាក្យសរសើរដែលកើតឡើង មិនថ្នាំងថ្នាក់ក្នុងចិត្តនឹងពាក្យនិន្ទា, មិនត្រេកអរនឹងសេចក្ដីសុខដែលកើតឡើង មិនថ្នាំងថ្នាក់ក្នុងចិត្តនឹងសេចក្ដីទុក្ខ ៚

អរិយសាវកនោះ លោកលះបោលសេចក្តីត្រេកអរនឹងសេចក្តីថ្នាំងថ្នាក់ក្នុងចិត្ត, ដូចពណ៌នាមកហើយយ៉ាងនេះ ទើបរួចចាកជាតិ ជរា មរណៈ សេចក្តីសោកខ្សឹកខ្សួល ទុក្ខទោមនស្ស សេចក្តីចង្អៀតចង្អល់ទាំងឡាយបាន, តថាគតហៅថា អរិយសាវកនោះរួចចាកទុក្ខមែន ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង នឹងបុថុជ្ជនអ្នកមិនចេះដឹង, មានសេចក្តីប្លែកគ្នា លើសខ្ពស់ជាងគ្នា ខ្ពស់ទាបជាងគ្នាដូច្នេះឯង ។

(អស់សេចក្តីក្នុងបាលីតែប៉ុណ្ណេះ)

នឹងអធិប្បាយតាមន័យក្នុងព្រះសូត្រនោះដូចមានតទៅនេះ សេចក្តីថាៈ លោកធម៌ទាំង ៨ ប្រការនេះ ចែកចេញជា ២ ផ្នែក គឺខាងគុណ ១ ផ្នែក ខាងទោស ១ ផ្នែក ។

ផ្នែកខាងគុណ (ខ្ពស់) បានដល់លោកធម៌ ៤ យ៉ាង គឺមានលាភ ១ មានយស ១ ពាក្យសរសើរ ១ សេចក្តីសុខ ១ រួមជា ៤ យ៉ាង ។

លាភៈ បានដល់របស់ដែលមានវិញ្ញាណ នឹងឥតវិញ្ញាណ ដូចបុត្រប្រុស- ស្រី- ខ្ញុំកំដរ- សំពត់ស្បៀង- ដណ្តប់- ភោជនាហារជាដើម ដែលបានមកដោយកំឡាំងព្យាយាមខ្លះ ដោយគុណវិជ្ជាសិល្បសាស្ត្រខ្លះ ដោយបុណ្យកុសលនាពីព្រេងនាយខ្លះ របស់ដែលបានមកនោះ ហៅថាលាភ ។ (មានត)

## លោកធម្មសូត្រ

(តមក)

សេលោ យថា ឯកឃនោ វាតេន ន សមីរតិ

ឯវំ និន្ទា បសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា[1] ។

(ប្រែថា) ភ្នំជាវិការនៃថ្មសុទ្ធមិនរំកើបញាប់ញ័រដោយខ្យល់ទាំង ៤ ទិស មានទិសបូព៌ាជាដើម (ដែលបក់មកត្រូវ) យ៉ាងណាមិញ, អ្នកប្រាជ្ញទាំងឡាយ លោកមិនរំកើបញាប់ញ័រក្នុងលោកធម៌ទាំង ៨ ប្រការ គឺមានលាភឥតលាភជាដើមយ៉ាងនោះដែរ ។

ក្នុងបទគាថានេះ បើតាមរបៀបក្នុងបាលីមានតែត្រឹមលោកធម៌ពីរប្រការ គឺនិន្ទានិងបសំសា ក៏ពិតមែន តែក្នុងអដ្ឋកថាមានសេចក្ដីពន្យល់ថា ត្រូវជាប់រហូតដល់លោកធម៌ទាំង ៨ ប្រការនោះផងចុះ ។

មិនតែប៉ុណ្ណោះសោត ព្រះអដ្ឋកថាលោកសំដែងជូនថែមទៀតថា:

សេលោ យថា ឯកឃនោ វាតេន ន សមីរតិ

ឯវំ រូបា រសា គន្ធា សទ្ទា ផស្សា ច កេវលា

ឥដ្ឋា ធម្មា អនិដ្ឋា ច នប្បវេធេន្តិ តាទិនោ

ឋិតំ ចិត្តំ វិប្បមុត្តំ វយញ្ចស្សានុបស្សតោ[2] ។

(ប្រែថា) ភ្នំជាវិការនៃថ្មសុទ្ធមិនរំកើបញាប់ញ័រដោយខ្យល់ទាំង ៤ ទិសមានទិសបូព៌ាជាដើម (ដែលបក់មកត្រូវ) យ៉ាងណាមិញ, រូប

---

១— ធម្មបទ បណ្ឌិតវគ្គលកុណ្ឌកភទ្ទិយត្ថេរ ។ ២ ឆក្កង្គុត្តរ ទុតិយបណ្ណាសក. បឋមវគ្គ. ធម្មក្ខន្ធក: មហាវគ្គ. សោណត្ថេរ ។

សំឡេង-ក្លិន-រស-ផស្សៈ និងធម្មារម្មណ៍ទាំងអស់ ដែលជាទីគាប់ចិត្តក្តី មិនជាទីគាប់ចិត្តក្តី នឹងញុំាងចិត្តរបស់ភិក្ខុជាតាទិបុគ្គល (១) ឲ្យញាប់ញ័រ មិនបានឡើយនោះដែរ, ចិត្តរបស់ភិក្ខុនោះជាចិត្តនៅខ្ជាប់ខ្ជួន ជាចិត្តយាង ចុះស៊ប់ក្នុងព្រះនិព្វានជាអារម្មណ៍, លោកពិចារណានូវសេចក្តីកើតនឹង សេចក្តីរលត់នៃចិត្តនោះ ។

គាថាទាំង ២ បទដែលកប់ជាជាមង្គលនេះ គាថាទី ១ ទ្រង់ប្រារព្ធនឹង លកុណ្ដកភទ្ទិយត្ថេរដែលលោកមិនរំភើបញាប់ញ័រ អាក់អន់ស្រពន់ចិត្ត ក្នុងពាក្យចំអកចំអន់ឡកឡឺយជាពាក្យឥតប្រយោជន៍, ដែលភិក្ខុកំឡោះ នឹងសាមណេរទាំងឡាយឃើញព្រះថេរៈនោះលោកតឿ ក៏នាំគ្នានិកសាន ជាសាមណេរតូច ខ្លះទាញចុងដៃ ខ្លះទាញចុងស្លា ខ្លះហៅលោកពូ ខ្លះ ហៅលោកតា ហើយសួរថា លោកមិនអផ្សុកទេឬអ្វី ? លោកក៏មិនរំភើប ញាប់ញ័រក្នុងពាក្យចំអកចំអន់នោះ ។ ទើបព្រះដ៏ទ្រង់យសទ្រង់ សំដែងសរសើរថាចិត្តនេះហើយជាមង្គល ។

គាថាទី ២ ទ្រង់ប្រារព្ធនឹងព្រះសោណត្ថេរ កាលដែលលោកបាន សម្រេចអរហត្តផលរួចហើយ ទើបប្រកាសសេចក្តីប្រារព្ធចំពោះអាត្មា ឯងថ្វាយព្រះដ៏មានព្រះភាគថា ចំនៀមព្រះវិណា ស្រពដែលមានចិត្ត

---

១ បុគ្គលដែលមិនញាប់ញ័រដោយសេចក្តីត្រេកអរ នឹងសេចក្តីអាក់អន់ចិត្តក្នុងអារម្មណ៍ជា ទីគាប់ចិត្ត នឹងអារម្មណ៍មិនជាទីគាប់ចិត្ត ។

ផុតចាក រាគៈ ទោសៈ មោហៈ ហើយ លោកទាំងនោះមិនបានកើតញាប់ញ័រដោយអារម្មណ៍ទាំង៦ មានរូបារម្មណ៍ជាដើម មានធម្មារម្មណ៍ជាទីបំផុតសោះឡើយ ។

ទើបព្រះអដ្ឋកថាចារ្យនិពន្ធគាថានេះទុកថា "សេលោ យថា ឯកឃនោ" ប៉ុណ្ណោះជាដើម តាមទំនងព្រះពុទ្ធដីកាដូចទ្រង់សំដែងហើយនោះ, សុភាពចិត្តនេះជាមង្គល ។ សុភាសិតទាំង២នេះ មូលសេចក្ដីទៅលើចិត្តរបស់ព្រះខីណាស្រពទាំងអស់ ។

ចប់ សេចក្ដីក្នុងមង្គលសូត្រប៉ុណ្ណោះ ។

ដំណពីនេះ នឹងរៀបរៀងសេចក្ដីជាបកិណ្ណកៈដែលជាប់ទាក់ទងដោយលោកធម៌របស់បុថុជ្ជននឹងព្រះខីណាស្រព ដើម្បីជាគ្រឿងប្រ-ដាប់បញ្ញារបស់សិក្ខាកាមកុលបុត្រអ្នកត្រូវការនឹងយកជាវត្តប្រតិបត្តិបានដោយងាយ ដូចនឹងមានតទៅនេះ ។

## មិលិន្ទបញ្ហា. លាភវគ្គ.

## ១ រឿងដាស់តឿនចំពោះលោកធម៌.

ដំណាលសេចក្ដីថាៈ ព្រះបាទមិលិន្ទទ្រង់ពោលដណ្ដឹងសួរគេអង្គរបស់យុត្តាថាមានប៉ុន្មាន? ព្រះនាគសេនត្ថេរតបថា មានអង្គ២ ដោយបរិយាយថា បពិត្រមហារាជ ធម្មតាយុត្តារមែងតែនឹងនិងលិចចុះក្នុងកក់ខ្ទប់ខ្ទល់នាក់មិនឲ្យកើតញាប់ញ័រដោយលោក-ខ្យល់ព្យុះដែលបក់បោក

មកគ្រប, ហើយរក្សានាវមិនឲ្យសាត់អណ្តែតទៅកាន់ទិសផ្សេង ១ បាន ដូចម្តេចមិញ; បពិត្រមហាកុដ!' ព្រះយោគាវចរលោកកំណត់ចិត្តរបស់លោកមិនឲ្យចិត្តសាត់អណ្តែតទៅកាន់អារម្មណ៍ផ្សេង ១ ដោយរលកគឺ រាគៈ ទោសៈ មោហៈ មកប្រហារឡើយ, ដូចយុថ្កាដែលទប់ទល់នាវឲ្យនឹងនៅក្នុងមហាសមុទ្រដូច្នោះដែរ នេះជាអត្ថទី ១ ។

មួយទៀតមហារាជ ធម្មតាយុថ្កាមិនឃ្លេងឃ្លោងលិចនៅតែក្នុងទឹកជំរៅ ១០០ ហត្ថ (២០០ ហត្ថ) ទប់ទល់នាវឲ្យនឹងនៅ ដូចម្តេចមិញ; ព្រះយោគាវចរមិនឃ្លេងឃ្លោងក្នុងលាភ-យស-សក្ការៈ-រាប់អាន-ថ្វាយបង្គំ-គោរពក្រែងឡើយ, លោកដំកល់ចិត្តរបស់លោកឲ្យនឹងនៅក្នុងបច្ច័យ ៤ ត្រាន់តែល្មមនឹងចិញ្ចឹមជីវិតប៉ុណ្ណោះ; ដូចជាយុថ្កាដែលទប់ទល់នាវឲ្យនឹងនៅក្នុងមហាសមុទ្រ ដូច្នោះដែរ នេះជាអត្ថទី ២ ។

សមដូចភាសិតរបស់ព្រះសារីបុត្តថា:

យថា សមុទ្ទេ លគ្គនំ[1] ន បលវតិ បសីទតិ[2]
តថេវ លាភសក្ការេ មា បលវថ បសីទថ ។

អធិប្បាយថា: ធម្មតាយុថ្កាមិនឃ្លេងឃ្លោង តែងនឹងលិចចុះក្នុងទឹកសមុទ្រ យ៉ាងណាមិញ; អ្នកទាំងឡាយកុំឃ្លេងឃ្លោងលិចចុះក្នុងលាភនឹងសក្ការៈឡើយ ដូចជាយុថ្កាដូច្នោះឯង ។

ចប់រឿងគាស់តឿងចំពោះលោកធម៌តែប៉ុណ្ណោះ ។

---

១ ច្បាប់ខ្លះថា " លគ្គនោ " ។ ២ ច្បាប់ខ្លះថា " វិសីទតិ " ដូច្នេះក៏មាន ។

ធម្មបទ កោធវគ្គ

## ២_រឿងអតុលឧបាសក[១]

មានសេចក្តីដំណាលថា: គ្រាកាលព្រះបរមគ្រូទ្រង់គង់ធរមាននៅឡើយនោះ, សម័យមួយស្តេចទ្រង់ប្រថាប់នៅក្នុងវត្តជេតពន កាលនោះមានឧបាសកម្នាក់ឈ្មោះអតុលៈនៅក្នុងក្រុងសាវត្ថី, ថ្ងៃមួយគាត់នាំគ្នាប្រហែលជា ៥០០ នាក់ទៅវត្ត ប្រុងនឹងស្តាប់ធម៌ក្នុងសំណាក់ព្រះរេវតត្ថេរ លុះទៅដល់ហើយក៏នាំគ្នាថ្វាយបង្គំអង្គុយចុះក្នុងទីដ៏សមគួរ ។

ឯព្រះរេវតត្ថេរលោកជាអ្នកត្រេកអរតែក្នុងទីស្ងាត់ ប្រៀបគួរនាដូចជាសត្វសីហៈចូលចិត្តត្រាច់ទៅតែឯកឯង ; បានជាលោកមិនធ្វើបដិសណ្ឋារៈតិចតួចជាមួយនឹងឧបាសកនោះឡើយ គេក៏ទើងអន់ចិត្តថាព្រះថេរៈនេះលោកមិននិយាយនឹងឯងមួយម៉ាត់សោះ; ក៏ក្រោកឡើងដើរទៅកាន់សំណាក់ព្រះសារីបុត្តត្ថេរ ។ លោកសួរថាអ្នកមកត្រូវការអ្វី? គេក៏ពិតថេរក់ពាថា លោកម្ចាស់ខ្ញុំនាំឧបាសកទាំងនេះមកកាន់សំណាក់ព្រះរេវតត្ថេរប្រុងស្តាប់ធម៌លោក ។ មិនអើពើនឹងយើងខ្ញុំសោះ ទើបយើងខ្ញុំអន់ចិត្តត្រឡប់មកកាន់សំណាក់លោកម្ចាស់វិញ សូមលោកម្ចាស់សំដែងធម៌ឲ្យពានយើងខ្ញុំ ។

---

១ អ្នកមិនចេះថ្វឹងលោកធម៌ ។

គ្រានោះ ព្រះសារីបុត្តលោកតបថា បើដូច្នោះចូរអ្នកនាំគ្នាអង្គុយប្រុងចាំស្តាប់ចុះ អាត្មានឹងសំដែងជូន លោកក៏សំដែងព្រះអភិធម្មឲ្យស្តាប់ គេក៏ទ្រាំងអន់ចិត្តទៀតថា ព្រះអភិធម្មនេះជាធម៌ល្អិតណាស់ ហ្មត់ចត់ណាស់ ព្រះថេរៈលោកសំដែងព្រះអភិធម្មយើងនឹងស្តាប់យកជាប្រយោជន៍ម្តេចបាន ហើយក៏ក្រោកឡើងនាំបរិស័ទរបស់ខ្លួនទៅកាន់សំណាក់ព្រះអានន្ទត្ថេរ ។ លោកក៏សួររាក់ទាក់ គេក៏ដំណាលរឿងតាមហូរហែ ហើយសូមនិមន្តព្រះអានន្ទសំដែងធម៌ឲ្យស្តាប់ ព្រះអានន្ទក៏ទទួលថា បើដូច្នោះចូរអ្នកនាំគ្នាអង្គុយប្រុងចាំស្តាប់ចុះ, ហើយលោកសំដែងធម៌ខ្លីៗ មានប្រមាណតិច គួរនឹងស្តាប់បានដោយងាយ ។

ឯឧបាសកទាំងនោះ ក៏ទ្រាំងអន់ចិត្តទៀត នាំគ្នាក្រោកឡើងដើរទៅកាន់សំណាក់ព្រះបរមសាស្តាវិញ, ទើបព្រះបរមសាស្តាទ្រង់ត្រាស់សួរថា អ្នកទាំងអស់គ្នាមកនេះដោយត្រូវការអ្វី? គេក៏ក្រាបបង្គំទូលថា ខ្ញុំព្រះអង្គទាំងអស់គ្នាមកនេះត្រូវការនឹងស្តាប់ធម៌ ! ព្រះអង្គទ្រង់ត្រាស់សួរទៀតថា ចុះអ្នកបានស្តាប់ហើយឬនៅទេ? គេក៏ក្រាបបង្គំទូលរៀបរាប់តាំងអំពីរឿងដើមមកថា ខ្ញុំព្រះអង្គទាំងអស់គ្នានេះទៅកាន់សំណាក់ព្រះរេវតត្ថេរ ។ លោកមិនអើពើនឹងយើងខ្ញុំព្រះអង្គសោះ យើងខ្ញុំក៏ទ្រាំងអន់ចិត្តនាំគ្នាទៅកាន់សំណាក់ព្រះសារីបុត្តត្ថេរ ។ លោកសំដែងព្រះអភិធម្មច្រើនពេកយើងខ្ញុំចាំធម៌នោះមិនបាន ក៏ទ្រាំងអន់ចិត្តត្រឡប់មកកាន់សំណាក់

ព្រះអានន្ទត្ថេរ ។ លោកសំដែងធម៌តិចពេក យើងខ្ញុំអន់ចិត្តត្រឡប់មកកាន់សំណាក់ព្រះអង្គនេះ ។

ព្រះបរមគ្រូបានទ្រង់សណ្ដាប់ពាក្យរបស់អតុលឧបាសកនោះហើយ, ទើបទ្រង់មានព្រះតម្រាស់ថា អតុល !! និន្ទានិងសរសើរនេះជារបស់មានមកហើយតាំងពីបុរាណនាយម្ល៉េះ; ជនពួកខ្លះតិះដៀលអ្នកនៅស្ងៀម, ខ្លះតិះដៀលអ្នកនិយាយច្រើន, ខ្លះតិះដៀលអ្នកនិយាយតិច ត្រង់អ្នកដែលគួរគេនិន្ទាសុទ្ធ ឬគួរគេសរសើរសុទ្ធតែចំណែកមួយឥតមានសោះឡើយ; ជនពួកខ្លះតិះដៀលព្រះមហាក្សត្រ, ខ្លះសរសើរព្រះមហាក្សត្រ ខ្លះតិះដៀលមហាប្រថពី, ខ្លះសរសើរមហាប្រថពី; ខ្លះតិះដៀលព្រះចន្ទព្រះអាទិត្យ, ខ្លះសរសើរព្រះចន្ទព្រះអាទិត្យ; ខ្លះតិះដៀលអាកាស, ខ្លះសរសើរអាកាស; ជនពួកខ្លះនិន្ទាព្រះសម្មាសម្ពុទ្ធដែលគង់ក្នុងកណ្ដាលបរិស័ទទាំង ៤ ហើយសំដែងធម៌, ខ្លះសរសើរព្រះអង្គវិញ; ព្រោះហេតុហ្នឹងហើយ ពាក្យនិន្ទាក្ដី ពាក្យសរសើរក្ដី របស់ពួកជនពាលនឹងយកជាប្រមាណពុំបានទេ; ឯចំណែកអ្នកប្រាជ្ញបើលោកនិន្ទាហើយ ឈ្មោះថានិន្ទាមែន, បើលោកសរសើរហើយ, ឈ្មោះថាសរសើរមែនឥតប្រែប្រួលឡើយ, លុះទ្រង់មានព្រះតម្រាស់ដូច្នោះហើយ ទើបទ្រង់សំដែងគាថានេះតទៅទៀតថា:

( មានត )

## លោកធម្មសូត្រ

## ព្រះគ្រូញាណសំវរៈ ញាណ-ឈឺន

(តមកនិងចប់)

បោរាណមេតំ អតុល នេតំ អជ្ជតនាមិវ
និន្ទន្តិ តុណ្ហិមាសីនំ និន្ទន្តិ ពហុភាណិនំ
មិតភាណិម្បិ និន្ទន្តិ នត្ថិ លោកេ អនិន្ទិតោ
ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ
ឯកន្តំ និន្ទិតោ បោសោ ឯកន្តំ វា បសំសិតោ
យញ្ចេ វិញ្ញូ បសំសន្តិ អនុវិច្ច សុវេ សុវេ
អច្ឆិទ្ទវុត្តិ(១) មេធាវី បញ្ញាសីលសមាហិតំ
និក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោ ។

សេចក្តីថា: អតុលៈ និន្ទានិន្ទាសរសើរនេះជារបស់មានមកហើយពីបុរាណនាយម្ល៉េះ និន្ទានិន្ទាសរសើរនេះមិនមែនទើបតែនឹងមានក្នុងថ្ងៃនេះទេ; ជនពួកខ្លះតិះដៀលអ្នកនៅស្ងៀមថាអើហ្ន៎! អ្នកនេះអង្គុយនៅតែស្ងៀមដូចមនុស្សគ ដូចមនុស្សថ្លង់ ដូចមនុស្សមិនដឹងអ្វីសោះ; ខ្លះតិះដៀលអ្នកនិយាយច្រើនថាអើហ្ន៎! អ្នកនេះនិយាយមិនចេះចប់ ប្រហែល

---

១ ច្បាប់ខ្លះថា "អច្ឆិន្នវុត្តិ" ដូច្នេះក៏មានដែរ ។

ដូចជាខ្យល់ប្រហារស្ទើរគោគព្រួសប៉ុប៉ង ម្ល៉េះ; ខ្លះតិះដៀលអ្នកនិយាយតិចថា អើហ្ន៎! អ្នកនេះស្មានថាពាក្យសំដីរបស់ខ្លួនថ្លៃប្រហែលគ្នានឹងមាសប្រាក់ ទើបនិយាយតែ ១ ម៉ាត់ ២ ម៉ាត់ក៏ស្ងៀមទៅ; មនុស្សយើងក្នុងលោកនេះដែលថាគេមិនតិះដៀលនោះមិនមានសោះឡើយ, ម្យ៉ាងទៀតមនុស្សដែលគេនិន្ទាតែ ១ ចំណែកសុទ្ធ ឬដែលគេសរសើរតែ ១ ចំណែកសុទ្ធ មិនមែនមានហើយតែក្នុងអតីតមិនមែននឹងមានតែក្នុងអនាគត មិនមែនទើបតែនឹងមានក្នុងបច្ចុប្បន្ននេះទេ ។

ឯចំណែកបណ្ឌិតទាំងឡាយ លោកតែងពិនិត្យៗ ដឹងស្គាល់ច្បាស់នូវពាក្យនិន្ទានិងពាក្យសរសើរ ហើយទើបលោកសរសើរនូវភិក្ខុណាដែលជាអ្នកប្រព្រឹត្តមិនដាច់ ព្រោះខ្ជាប់ខ្ជួនក្នុងសិក្ខាផង ក្នុងកិច្ចបំពេញវត្តផង ជាអ្នកមានបញ្ញា ព្រោះប្រកបដោយបញ្ញាដែលកើតតាមផ្លូវធម៌[១](ផង) ជាអ្នកតាំងខ្លួនក្នុងសីលនិងបញ្ញា ព្រោះប្រកបដោយលោកិយបញ្ញា និងលោកុត្តរបញ្ញាផង; ដោយចតុប្បារិសុទ្ធិសីលផង, អ្នកណាមួយនឹងតិះដៀលនូវភិក្ខុនោះ ដូចមនុស្សអ្នកតិះដៀលនូវមាសជម្ពូនទ [២] ដែលគេដុសខាត់ហើយ ជាមាសឥតមានមន្ទិលដូច្នោះបាន សូម្បីទេវតានិងមនុស្សជាបណ្ឌិតទាំងឡាយក៏តែងសរសើរនូវភិក្ខុនោះដែរ

---

១ ផ្លូវ ២ យ៉ាងគឺគតិលោក ១ គតិធម៌ ១ ក្នុងទីនេះសំដៅយកប្រាជ្ញាដែលចេះដឹងតាមធម៌ អាចផ្ចាញ់ផ្ចាលសត្រូវគឺកិលេសបាន (មតិ) ។ ២ មាសដែលកើតមកអំពីផ្លែព្រីង ឬដើមព្រីង (អភិធាន) ។

មិនមែនត្រឹមតែទេវតានិងមនុស្សប៉ុណ្ណោះ តាំងមហាព្រហ្មក្នុងម៉ឺនចក្រវាឡក៏គង់សរសើរដែរ ។

លុះព្រះភគវន្តមុនីទ្រង់ត្រាស់ភាសិតនេះចប់ហើយ ទើបឧបាសកទាំង៥០០នាក់ មានអតុលឧបាសកជាដើមនោះ (បានស្តាប់ហើយ) ក៏បានតាំងនៅក្នុងគុណគឺសោតាបត្តិផលទាំងអស់គ្នា (ក្នុងកាលនោះឯង) ។

ចប់រឿងអតុលឧបាសកតែប៉ុណ្ណោះ ។

---

## ធម្មបទ យមកវគ្គ

## ៣ រឿងព្រះនន្ទ ( សំដែងសេចក្ដីសរសើរ )

សេចក្ដីដំណាលថា: កាលនៅក្នុងបឋមពោធិកាលគឺកាលដែលព្រះពុទ្ធអង្គទើបនឹងបានត្រាស់ដឹងថ្មី ៗ ក្នុងលោក ។

សម័យមួយទ្រង់ពុទ្ធដំណើរចូលទៅក្នុងក្រុងកបិលពស្តុ ទ្រង់បានបំបួសសក្យត្រកូលពីរអង្គគឺព្រះនន្ទសក្ក ១ ព្រះរាហុល ១; លុះទ្រង់ប្រថាប់នៅក្នុងក្រុងនោះតាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទើបទ្រង់គមនាការត្រឡប់មកកាន់ក្រុងសាវត្ថីវិញ សម្រេចឥរិយាបថនៅក្នុងក្រុងនោះ ។

ឯចំណែកនន្ទភិក្ខុក៏តាំងធ្វើព្យាយាមចំរើនសមាធិធម៌ ដរាបដល់បានសម្រេចព្រះអរហត្តផលបានជាអរហន្តអង្គ ១ ដែរ, ទើបលោកចូលទៅគាល់ព្រះសុគតជាម្ចាស់ ហើយក្រាបបង្គំទូលតាមរឿងដើមគ្រប់ប្រការ ។

ព្រះលោកនាថជាម្ចាស់បានទ្រង់ព្រះសណ្ដាប់ពាក្យព្រះនន្ទត្ថេរ នោះហើយ ទើបទ្រង់មានពុទ្ធត្រាស់ថា តថាគតក៏បានដឹងហើយដែរ តាំងទេវតាទាំងឡាយក៏នាំសេចក្ដីនោះមកប្ដឹងតថាគតទៀតថា "អាយស្មា ភន្តេ នន្ទោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ" សេចក្ដីថា: បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះនន្ទដ៏មានអាយុ លោកបានត្រាស់ដឹងធ្វើឲ្យច្បាស់នូវចេតោវិមុត្តិ[1] បញ្ញាវិមុត្តិ[2] ដោយខ្លួនឯងក្នុងបច្ចុប្បន្ននេះហើយ លោកនៅសម្រេចឥរិយាបថស្រួលបួលហើយ ។

គ្រានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានជ្រាបដំណើរនោះច្បាស់លាស់ហើយ ទើបទ្រង់បន្លឺនូវឧទានគាថាក្នុងវេលានោះថា:

យស្ស តិណ្ណោ កាមបង្កោ មទ្ទិតោ កាមកណ្ដកោ
មោហក្ខយមនុប្បត្តោ សុខទុក្ខេ ន វេធតីតិ ។

សេចក្ដីថា: បុគ្គលណាឆ្លងផុតភក់គឺកាមហើយ កាច់បំបាក់ញាំញីនូវបន្លាគឺកាមហើយ អស់មោហៈគឺអវិជ្ជាតាមលំដាប់ហើយ បុគ្គលនោះមិនបានរំភើបញាប់ញ័រក្នុងសេចក្ដីសុខ និងសេចក្ដីទុក្ខទៀតឡើយ ។

ចប់រឿងព្រះនន្ទតែប៉ុណ្ណេះ ។

---

១– អរហត្តផលសមាធិ ។ ២– អរហត្តផលវិបស្សនា ។

## ៤ – រឿងព្រះសារីបុត្ត (សំដែងសេចក្ដីស្ងៀបស្ងប់ស្ងៀម)

មានសេចក្ដីដំណាលថា: គ្រាកាលព្រះបរមគ្រូទ្រង់គង់ធរមាននៅឡើយ សម័យមួយស្ដេចទ្រង់ប្រថាប់នៅក្នុងវត្តជេតពន, កាលនោះព្រះសារីបុត្តដ៏មានអាយុ លុះដល់ចេញវស្សារួចហើយលោកមានបំណងនឹងនិមន្តចេញទៅកាន់ចារិក (និគមជនបទតូច-ធំ) ទើបទៅថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ហើយចេញទៅជាមួយនឹងភិក្ខុជាបរិវាររបស់លោក ។

លំដាប់នោះ ព្រះថេរៈលោកនឹកហៅឈ្មោះពួកភិក្ខុដែលលោកស្គាល់ច្បាស់លាស់ដោយនាមនឹងគោត្រហើយទើបចេញទៅ, មានភិក្ខុ ១ រូបនៅក្នុងចំណោមនោះ, មានបំណងថា "អើហ្ន៎! ព្រះមហាថេរលោកនឹងរាប់ឈ្មោះអាត្មាដែរដេង, ឯព្រះថេរៈលោកមិនបានហៅឈ្មោះភិក្ខុនោះដោយនាមនឹងគោត្រឡើយ ព្រោះក្នុងកណ្ដាលទីប្រជុំធំ, ភិក្ខុនោះក៏ខឹងអន់ចិត្តនឹងព្រះថេរៈថា "លោកមិនរាប់យកឈ្មោះអាត្មាដូចភិក្ខុឯទៀតផងនោះ" ស្រាប់តែនៅវេលានោះជាយសង្ឃាដីរបស់ព្រះសារីបុត្ត មកពាល់ត្រូវសរីរៈភិក្ខុនោះៗ ក៏ចងអាឃាតដោយហេតុប៉ុណ្ណោះឯង ។ លុះកាលតមកភិក្ខុនោះដឹងថា ឥឡូវនេះព្រះសារីបុត្តលោកត្រឡប់មកអំពីនិគមទីនិមន្តមកកាន់វត្តវិញ ខ្លួនក៏ចូលទៅគាល់ព្រះពុទ្ធជាម្ចាស់ហើយ

ក្រាបបង្គំទូលថា "បពិត្រព្រះអង្គដ៏ចំរើន, ព្រះសារីបុត្តដ៏មានអាយុ លោកប្រហារខ្ញុំព្រះអង្គជិតនឹងធ្លាយត្រចៀក ដោយប្រកាន់ថាខ្លួនជាអគ្គសាវករបស់ព្រះអង្គ លោកមិនទាន់សូមខមាទោសនឹងខ្ញុំព្រះអង្គ ស្រាប់តែនិមន្តចេញទៅកាន់ចារិកហួសទៅ" ។

ព្រះបរមសាស្តា ក៏ទ្រង់ត្រាស់ឲ្យហៅព្រះសារីបុត្តមក ដើម្បីនឹងបញ្ជាក់រឿងនោះ ក៏ក្នុងវេលានោះព្រះមហាមោគ្គល្លានត្ថេរក្តី ព្រះអានន្ទ-ត្ថេរក្តីគិតគ្នាថា "ទំនងជាព្រះបរមគ្រូទ្រង់ពុំទាន់បានជ្រាបនូវកិច្ចនេះ ដែលព្រះសារីបុត្តជាបងរបស់យើងមិនបានប្រហារទេដឹង, ទាំងទ្រង់មិនចង់ប្រទាននូវសីហនាទដែរទេដឹង", ទើបព្រះថេរៈទាំងនោះកាន់យកនូវកូនសោទៅបើកទ្វារបន្ទប់ហើយប្រជុំភិក្ខុសង្ឃដោយស្រែកថា "លោកដ៏មានអាយុទាំងឡាយនាំគ្នាប្រញាប់ចេញទៅ, លោកដ៏មានអាយុទាំង-ឡាយនាំគ្នាប្រញាប់ចេញទៅ, ឥឡូវនេះព្រះសារីបុត្តដ៏មានអាយុលោកនឹងបន្លឺនូវសីហនាទចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ" ។

ឯព្រះសារីបុត្តក៏មកថ្វាយបង្គំព្រះបរមសាស្តាហើយគង់នៅស្ងៀម, ទើបព្រះបរមសាស្តាទ្រង់ត្រាស់សួរដំណើរនោះនឹងព្រះសារីបុត្ត ។ លោកមិនបានប្រកែកថា "ខ្ញុំព្រះអង្គឥតបានប្រហារទេដូច្នេះឡើយ" ត្រ-ឡប់បែរទៅសំដែងនូវគុណរបស់លោកវិញថា "បពិត្រព្រះអង្គដ៏ចំរើន បុគ្គលណាបានតាំងកាយគតាសតិក្នុងកាយរឿយៗ ហើយ បុគ្គលនោះ

តែងជាប់ជំពាក់ទៅក្នុងសព្រហ្មចារីណាមួយមិនហ៊ានលះបោលឡើយ ហើយត្រូវតែត្រាច់ទៅកាន់ចារិក ។ ទើបលោកប្រកាសចិត្តដែលស្មើដោយផែនដីផង ស្មើដោយទឹក-ភ្លើង-ខ្យល់និងកុមារតូចអ្នកលេងធូលីនិងគោបាក់ស្នែងផង ដោយន័យថា "បពិត្រព្រះអង្គដ៏ចំរើន តាម. ទារកទាំងឡាយតែងចាក់ចុះនូវរបស់ស្អាតក្តី មិនស្អាតក្តី, ផែនដីមិនត្រេកអរ មិនទោមនស្សដូចម្តេចមិញ ខ្ញុំព្រះអង្គក៏ដូច្នោះឯង ទើបលោកប្រកាសសេចក្តីនឿយណាយក្នុងកាយ ដូចគេនឿយណាយសាកអសុភពស់ផង នូវការរក្សាកាយ ដូចគេរក្សាឆ្នាំងដីផង'' ។

កាលបើព្រះថេរៈលោកសំដែងគុណរបស់លោកដោយឧបមាទាំង ៩ រឿងនេះចប់ហើយ ផែនដីក៏ញាប់ញ័រអស់វារៈ ៩ ដងដែរ, នៅវេលាដែលព្រះថេរៈប្រៀបផ្ទឹមចិត្តរបស់លោកដោយកុមារតូចអ្នកលេងធូលីនិងអ្នករក្សាឆ្នាំងដីប៉ុណ្ណោះ, ពួកភិក្ខុជាបុថុជ្ជនអត់ទ្រាំពុំបានក៏យំសម្រក់ទឹកភ្នែក, ពួកភិក្ខុជាព្រះខីណាស្រពក៏កើតមានសេចក្តីសង្វេគ, លុះព្រះសារីបុត្តសំដែងគុណរបស់លោកចប់ហើយ ភិក្ខុអ្នកពោលបង្កាច់នោះកើតក្តៅក្រហាយពេញក្នុងសរីរៈដូចភ្លើងឆេះ, ក្រឡាប់ក្រាបក្បាលទៀបបាទាព្រះដ៏មានព្រះភាគក្នុងមួយរំពេចនោះ ប្រកាសសូមទោសដែលខ្លួនបានពោលបង្កាច់ហើយនោះ ។

ព្រះបរមសាស្ដាទ្រង់ត្រាស់ហៅព្រះសារីបុត្តថា "ម្នាលសារីបុត្ត ចូរអ្នកអត់ទោសដល់មោឃបុរសនេះផងចុះ បើអ្នកមិនអត់ទោសទេ មោឃបុរសនេះនឹងបែកក្បាលជា ៧ ភាគ" ។ ព្រះសារីបុត្តទទួលព្រះដីកាហើយ ក៏អង្គុយប្រហោងផ្គងអញ្ជលីមានថេរវាចាថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គអត់ទោសដល់លោកដ៏មានអាយុនេះហើយ; ប្រសិនបើខ្ញុំព្រះអង្គមានទោស ក៏សូមឲ្យភិក្ខុដ៏មានអាយុនេះអត់ទោសដល់ខ្ញុំព្រះអង្គដែរ"; ទើបភិក្ខុទាំងឡាយនិយាយសរសើរថា "ម្នាលអាវុសោទាំងឡាយ ឥឡូវនេះអ្នកចូរមើលព្រះសារីបុត្តចុះ លោកមានគុណមិនថោកថយឡើយ លោកមិនបានធ្វើសេចក្ដីក្រោធប្រទូស្ដដល់ភិក្ខុអ្នកពោលបង្កាច់នេះសោះ ត្រឡប់បែរទៅជាអង្គុយប្រហោងផ្គងអញ្ជលីសុំឲ្យភិក្ខុនេះ អត់ទោសវិញ" ។

ព្រះបរមសាស្ដាបានទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទើបទ្រង់សំដែងចិត្តព្រះសារីបុត្តថា "ចិត្តរបស់សារីបុត្តធ្ងន់ប្រហែលដូចផែនដី ប្រហែលដូចសសរខឿន ប្រហែលដូចអន្លង់ទឹកថ្លា", រួចហើយទ្រង់សំដែងគាថានេះតទៅទៀតថា:

បឋវីសមោ នោ វិរុជ្ឈតិ
ឥន្ទខីលូបមោ តាទិ សុព្វតោ

រហទោវ អបេតកទ្ទមោ

សំសារា ន ភវន្តិ តាទិនោ ។

ប្រែថា ក៏ឯអត្ថនៃគាថានេះ ព្រះលោកនាថជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពារកទាំងឡាយតែងទម្លាក់ដាក់ចុះនូវរបស់ស្អាត គឺគ្រឿងក្រអូបមានកម្រងផ្កាជាដើមក្តី នូវរបស់មិនស្អាតគឺមូត្រគូថជាដើមក្តី ទៅលើផែនដីយ៉ាងណា, តែងនាំគ្នាកៀកដកឡើងខ្លះ ជះដាន់បោះចុះទៅវិញខ្លះនូវសសរខឿនដែលគេបោះចុះត្រង់ទ្វារព្រះនគរ ក៏ដូច្នោះដែរ; ពួកខ្លះទៀតនាំគ្នាធ្វើសក្ការៈ ដោយគ្រឿងក្រអូបមានកម្រងផ្កាជាដើមនឹងសសរខឿននោះ, ឯផែនដីនឹងសសរខឿន មិនត្រេកអរមិនទោមនស្សព្រោះហេតុអស់នោះឡើយ មានឧបមាដូចម្តេចមិញ; ខីណាសវភិក្ខុបានឈ្មោះថាជាតាទិបុគ្គលព្រោះមិនរំភើបញាប់ញ័រដោយលោកធម៌ទាំង ៨ ប្រការជាអ្នកមានវត្តប្រតិបត្តិត្រឹមត្រូវ, ខីណាសវភិក្ខុនោះមិនមានត្រេកអរពេញចិត្តចំពោះបុគ្គលដែលធ្វើសក្ការៈរាប់អាន, ដោយលោកគិតថា "អ្នកទាំងនេះធ្វើសក្ការបូជាអាត្មាដោយបច្ច័យទាំង ៤" ទាំងមិនអាក់អន់ថ្នាំងថ្នាក់តូចចិត្តចំពោះបុគ្គលដែលមិនបានធ្វើសក្ការបូជា ដោយលោកនឹកថា :

អ្នកទាំងនេះមិនធ្វើសក្ការបូជាអាត្មា ដូច្នេះឡើយ មានឧបមេយ្យដូចផ្ទៃផែនដីនឹងសសរខឿន ដូច្នោះឯង ។

(១ វិញទៀត) ព្រោះមានចិត្តថា មិនគួរល្អក់យ៉ាងណាមិញ វិញ្ញាណសាវកភិក្ខុក៏មានសទ្ធាថា ព្រោះសាវកគួរល្អក់ គឺ រាគៈ ទោសៈ មោហៈ យ៉ាងដូច្នោះដែរ ។

ការអោឡារទៅមគ្គផលសុគតិនិងទុគ្គតិ រមែងមិនមានដល់វិញ្ញាណសាវកភិក្ខុមានសភាពដូច្នោះឡើយ ។

ចប់រឿងព្រះសារីបុត្តតែប៉ុណ្ណោះ ។

ពពភិរមាក្នុងលោកធម្មសូត្រចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

ព្រះគ្រូញាណសំវរ ញាណ-ឈឹន
ក្រុមជំនុំប្រែព្រះត្រៃបិដក ក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ
ប្រែនិងរៀបរៀងជាសេចក្តីទេសនា ។

ព.ស. ២៤៩៨ គ.ស. ១៩៥៣ ។

# លោកធម្មសូត្រ

(តមក)

យស: បានដល់ឥស្សរិយយស, បុណ្យអំណាច, បរិវារ, អាយុ-វ័យជាដើម របស់គ្រហស្ថបព្វជិត; ខាងបព្វជិតបានដល់សីលផុស នឹងឆ្នាំដែលបានឧបសម្បទហើយ ដូចលោកបួសថ្មីពីត្រឹម ៥ វស្សាចុះមក ជានវភិក្ខុ, ពីត្រឹម ៥ វស្សាឡើងទៅទល់នឹង ៩ វស្សាជាមជ្ឈិមភិក្ខុ, ពីត្រឹម ១០ វស្សាឡើងទៅជាថេរៈ; ទាំង ២ ន័យនេះ ហៅថា យស (ទីបទី) ។

សរសើរ បានដល់ពាក្យអំនួយដែលអ្នកក្រៅគេពេញចិត្តពេញគំនិត ដោយគុណរបស់ខ្លួនគុណណាមួយ ល្មមឲ្យគេអត់ធន់ទ្រាំពុំបាន គេក៏ពោលអំនួយជួយជ្រោងឡើងតាមគុណនោះ ។ គង់ទីចំពោះមុខខ្លះ កំបាំងមុខខ្លះ ហៅថា ពាក្យសរសើរ ។

សុខ: បានដល់សភាពដែលគួរឲ្យរីករាយ-ស្រស់ស្រាយ-ឈាមថ្លា មុខរីកញញឹមញញែម ដោយសមតាមបំណងតាមប្រាថ្នា ដូចដេក-ដើរ-ឈរ- អង្គុយជាដើម មិនមានសេចក្ដីលំបាកជាផលរបស់បុណ្យ ហៅថា សុខ ។

ទាំង ៤ យ៉ាងនេះ បើប្រគល់ផលឲ្យដល់ជនចំពួកណា ហើយនឹងធ្វើជនចំពួកនោះ ឲ្យមានសេចក្ដីត្រេកអរឡើងជំនោរ មានបុគ្គលពាលខ្លះ

ឬជាទីគោរពក្រាបដល់ជនឯទៀត ដោយមានលាភ-យស-ពាក្យសរសើរ-សេចក្តីសុខនោះឯង ។

ផ្នែកខាងទោស (ពាប) បានដល់លោកធម៌ ៤ យ៉ាង គឺ ឥតលាភ ១ ឥតយស ១ ពាក្យនិន្ទា ១ សេចក្តីទុក្ខ ១ ទាំង ៤ យ៉ាងនេះ បើប្រគល់ផលឲ្យដល់ជនចំពូកណាហើយ ទឹងធ្វើជនចំពូកនោះឲ្យមានសេចក្តីអាក់អន់តូចចិត្ត មានមុខក្រៀមក្រំឡើងឈាមទៅ ឥតអំណាចតេជះអ្វីតិចតួចក្នុងខ្លួន ពាបក្រៃលែងពាប ថោកក្រៃលែងថោក សាបក្រៃលែងសាប ដោយឥតមានទីសន្សឹមគុណណាមួយសោះ, ម្ល៉ោះហើយជនចំពូកនោះទទួលវេទនាព្រោះថ្នាក់តែផ្នែកខាងទោសមិនអាយខឹងរ៉ៃស្រន់ឡើងបានព្រោះខុសបំណងខុសប្រាថ្នាគ្រប់អន្លើទាំងអស់ ។

ផ្នែកទាំង ២ ដូចបានថ្លែងមកហើយនេះ តែងផ្លាស់ប្តូរវេនគ្នាវិលចុះវិលឡើងជាដរាប, បានជាព្រះពុទ្ធដីកាទ្រង់សំដែងថា: "អដ្ឋ លោក-ធម្មា លោកំ អនុបរិវត្តន្តិ លោកធម៌ទាំង ៨ ប្រការតែងជាប់ជិតដោយតាមសត្វលោកគ្រប់ជាន់គ្រប់ថ្នាក់" ដូចរៀបរៀងមកហើយក្នុងបាលីនោះ ។

ជនចំពូកមួយ បានទទួលត្រឹមតែផ្នែកខាងគុណសុទ្ធ ស្មើតែទឹងហេតុមួយដ៏តែក៏មានខ្លះ តែដោយស្តួចស្តើងណាស់, ជនចំពូកមួយ

ទទួលត្រូវនឹងតែបែកខាងទោសសុទ្ធ ស្ទើរតែនឹងរកហេតុមួយដ៏ពិតទៅក៏សឹងមានដោយប្រើន ។

បើចែកជាគូវិញមាន ៤ គូ លាយទាំងគុណទាំងទោស (ខ្ពស់ទាប) ប្រឡូកប្រឡំគ្នា គឺមានលាភ ឥតលាភជាគូ ១ មានយស ឥតយសជាគូ ១ សរសើរ និន្ទាជាគូ ១ សុខទុក្ខជាគូ ១ សេចក្តីពិស្តារដូចបានរៀបរៀងមកហើយក្នុងខាងលើស្រាប់ ។

ន័យមួយទៀតក្នុងគម្ពីរទីបនីអដ្ឋកថាមង្គលសូត្រត្រង់គាថាទី ១០ សេចក្តីថា :

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ
អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមន្តិ ។

(ប្រែថា) ចិត្តរបស់បុគ្គលឯណា ដែលលោកធម៌ទាំងឡាយ ពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្តីសោក ១ មិនមានធុលីគឺរាគៈ ១ ជាចិត្តក្សេមក្សាន្ត ១ ទាំង ៤ យ៉ាងនេះជាមង្គលដ៏ឧត្តម ។

ក៏ឯចិត្តនេះ[១] បើពោលតាមបាលីមាន ៦ យ៉ាងគឺ ចិត្តំ ចេតោ មនោ វិញ្ញាណំ ហទយំ មានសំ ជានាមធម៌ ១ យ៉ាងល្អិត មិនមានទ្រង់ទ្រាយពណ៌សម្បុរល្មមឲ្យឃើញ ចាប់ពាល់សំគាល់បានដោយ

---

១. សូមផ្ទៀងតាមព្រះអភិធម្ម ឬ វិសុទ្ធិមគ្គនោះចុះ ។

ឆាយទៀយ ត្រាន់តែមានសភាពគិតនឹករំពឹងបញ្ជូនទៅរកអារម្មណ៍ គេ ហេតុផ្សេងៗ ប៉ុណ្ណោះ ។

បើពោលតាមរូបសព្ទពាក្យប្រែវិញដូច្នេះគឺ:

១– ធម្មជាតគិតនឹកទៅរកអារម្មណ៍ ឬដឹងស្គាល់អារម្មណ៍ ឈ្មោះ ថា ចិត្ត ។

២– ធម្មជាតសន្សំអារម្មណ៍ ឬត្រាច់ទៅតាមអារម្មណ៍ ឈ្មោះថា ចេតោ ។

៣–. ធម្មជាតដឹងអារម្មណ៍ វាល់ទម្ងន់ វាស់ជំពៅ ថ្លឹង ស្ទង់ វៃលក ឬ អុំស្ទូអារម្មណ៍ ឈ្មោះថា មនោ ។

៤–. ធម្មជាតសម្រាប់ដឹង ស្គាល់អារម្មណ៍ដោយវិសេស ឈ្មោះ ថា វិញ្ញាណ ។

៥–. ធម្មជាតសម្រាប់ទទួលត្រងនូវអារម្មណ៍គឺសេចក្តីលំបាក-ល្អ-អាក្រក់-សុខ-ទុក្ខគ្រប់ប្រការ ឈ្មោះថា ហទយ ។

៦–. ធម្មជាតសម្រាប់ផ្តួចផ្តើម–ផ្គងគំនិត-បំណង-ប្រាថ្នា ឈ្មោះ ថា មានស:

រូបសព្ទទាំង ៦ យ៉ាងនេះ ផ្សេងគ្នាតែត្រង់ពាក្យប្រែ, ឯអត្ថសេចក្តី នៅតែមួយដូចគ្នា គឺចិត្តនេះឯង; សមដូចពាក្យថា ចិត្តបុណ្យ, ចិត្ត បាប, ចិត្តល្អ, ចិត្តអាក្រក់ ។ល។ បើពោលដោយកិច្ចរបស់ចិត្តវិញ

មាន៣យ៉ាង គឺសេចក្ដីសំគាល់ចាំបានថា: ស, ខៀវ, ក្រហម, ខ្មៅជាដើម ជាកិច្ចរបស់សញ្ញា[១]១, សេចក្ដីដឹងច្បាស់លាស់ថា: ស, ខៀវ, ក្រហម, ខ្មៅ រហូតដល់ដឹងត្រៃលក្ខណញ្ញាណ គឺ: អនិច្ចំ ទុក្ខំ អនត្តា តែមិនអាចនឹងធ្វើដំណើរទៅឈោងយកមគ្គ-ផលបានឡើយ ជាកិច្ចរបស់វិញ្ញាណ១, សេចក្ដីដឹងវិសេសជាងសញ្ញានិងវិញ្ញាណទាំងពីរនេះផង អាចនឹងធ្វើដំណើរទៅឈោងយកមគ្គ-ផល ព្រះនិព្វានបាន តាមចំនេងខ្លួនឯងផង ជាកិច្ចរបស់បញ្ញា (សោភណចេតសិក)១ ។ កិច្ចទាំង ៣ យ៉ាងនេះ មានគួរនាដូចជនទាំង៣ពួក គឺទារកតូចៗ១ មនុស្សធំដឹងក្ដី១ នាយជាងមាស ១ ។

ឯទារកតូចៗ បើប្រសិនជាបានឃើញរូបកហាបណៈ ឬរូបមាសគក៏ ត្រាន់តែដឹងថា វែង ខ្លី ជ្រុង មូល ខ្មៅ ស ត្រឹមប៉ុណ្ណោះក៏ផុតគំនិតទៅ មិនបានដឹងថាជារបស់ឥតដំឡៃមានដំឡៃ អ្នកប្រទេសគេតែងកប់អានទុកជាគ្រឿងឧបភោគ បរិភោគក៏ទេ ។

ចំណែកខាងមនុស្សធំដឹងក្ដី ទើបបានដឹងថា រូបកហាបណៈឬមាសគនេះ ជារបស់ល្អវិចិត្រ វែង ខ្លី ជ្រុង មូល ខ្មៅ ស ព្រមទាំងដឹងថារបស់នេះមានដម្លៃ អ្នកប្រទេសគេតែងនិយមកប់អានទុកជាគ្រឿងឧបភោគ

---

១ សព្វចិត្តសាធារណចេតសិកមាន ៧ គឺ: ផស្សោ, វេទនា, សញ្ញា, ចេតនា, ឯកគ្គតា, ជីវិតិន្ទ្រិយោ, មនសិការោ ។ អភិធម្ម ។

បរិភោគត្រឹមប៉ុណ្ណោះក៏ផុតគំនិតទៅ ទើបបានដឹងថារូបកហាបណៈ ឬមាសកនេះមានទីកខ្ពស់-ទាប មានសាច់ពេញលេញបរិសុទ្ធផូរផង់ ជាមាសក្រហម មាសសលាយដោយខន់ផែន ឬលាយដោយជាតិដទៃក៏ទេដែរ ។

ចំណែកខាងឯនាយជាងមាសវិញ ទើបដឹងស្គាល់ហេតុថារូបកហាបណៈឬមាសកនេះ មានទីកខ្ពស់ មានសាច់ពេញលេញបរិសុទ្ធផូរ-ផង់ ជាមាសក្រហមសុទ្ធ-សសុទ្ធឥតលាយដោយខន់ផែន ឬលាយដោយជាតិដទៃទេ មានថ្លៃត្រឹមប៉ុណ្ណោះៗ, កើតនៅលើភ្នំក្នុងសមុទ្រ ផុតខ្សាប់ ដំបន់ឯណោះៗ មិនមានងឿងឆ្ងល់ទីងគំនិតឡើយ ។

សញ្ញាប្រៀបនូវនាដូចទារកតូច ៗ, វិញ្ញាណដូចមនុស្សធំដឹងក្ដីកក់ក្ដៅ-ធ្ងន់ស្រាល,បញ្ញាដូចនាយជាងមាសស្គាល់ជាតិមាសមិនភាន់ច្រឡំដូច្នោះឯង ។

មួយវិញទៀត ចិត្តនេះបើពាត់ដោយសណ្ឋានពីសវិញ ក៏ពឹសណាស់ក្រៃលែងជាងសត្វពាន ឬក្រៃលែងជាងទារកតូច ដែលនៅដេកផ្ងារមិនទៀមស្ងាត់នៅក្នុងអារម្មណ៍មួយៗ ឡើយ ប្រហែលដូចសត្វមច្ឆជាតិត្រីដែលបុគ្គលស្រង់ឡើងដាក់លើគោក ហើយក៏រមែងទីងស្ទុះស្ទាទ្រេត្រាប្រឹងនឹងទៀលទៅរកទឹកវិញ មិនដោយទីងស្ងិតនៅនឹងឡើយ, ហើយជាធម្មជាតិតែងអាស្រ័យនៅជាមួយនឹងរូបមនុស្ស - សត្វតិរច្ឆាន - ទេវតា

ដោយច្រើន, ដូចមានសេចក្ដីក្នុងបរមត្ថថា នាម ១-រូប ១, រូបបានដល់រូបក្ខន្ធ, នាមបានដល់វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ, របស់ទាំងពីរនេះតែងជាប់ជិតដោយតាមគ្នាគ្រប់ ១ ជំណាក់, បើនាមបែរមុខឈមទៅកាន់ជំណាក់ខាងសុគតិ រូបក៏ទៅតាម, បើនាមបែរមុខឈមទៅកាន់ជំណាក់ខាងទុគ្គតិ រូបក៏ទៅតាមដូចម្លប់នឹងបេសដូច្នោះឯង ។

តែក្នុងទីនេះ មានបំណងនឹងសំដែងតែអំពីចិត្ត ដែលមិនរំកើបញាប់ញ័រដោយលោកធម៌ណាមួយមកប៉ះពាល់, ដែលរាប់ថាជាមង្គលប៉ុណ្ណោះ ព្រោះក្នុងបទគាថាទី ១០ នោះជាប់ទាក់ទងដោយមង្គល ៤ ប្រការ ដូចបានពណ៌នាមកហើយខាងលើស្រាប់ ។

ត្រង់ពាក្យថា: មង្គល បានដល់សេចក្ដីល្អ សេចក្ដីចំរើនសុខសាន្តត្រាណគ្រប់ជាន់គ្រប់ថ្នាក់ ទាំងលោកិយៈ លោកុត្តរៈ ហៅថា មង្គល ដូចគ្នានឹងពាក្យថា បុណ្យ-ផល កុសលានិសង្សនោះដែរ ។

ក៏ឯមង្គលទាំង ៤ ប្រការនោះ នឹងលើកមង្គល ៣ ទុក, សូមរៀបរៀងចំពោះតែអកម្បិតចិត្តមង្គល ១ ដូចមានតទៅនេះ ។

សេចក្ដីថា: ចិត្តរបស់បុគ្គលជំនាន់ណាមួយ ទោះបីបុថុជ្ជនក្ដី អរិយសាវកក្ដី ដែលជាចិត្តមិនរំកើបញាប់ញ័រដោយលោកធម៌ទាំង ៨ ប្រការ សូម្បីលោកធម៌ណាមួយ ចិត្តរបស់បុគ្គលនោះហៅថាមង្គល ដូចមានពុទ្ធភាសិតថា: (មានត)